**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:.................

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា នឹងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ **កិច្ចប្រជុំលើកទី១២ នៃ*គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ*** *( The 12th General Border Committee Meeting "GBC" ) នៅ*ខេត្តសៀមរាប ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ក្រោមអធិបតីភាពឯក ឧត្តម នាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា សហប្រធាន គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា និង ឯកឧត្តម នាយឧត្តមសេនីយ៍ **ប្រាវីត វង្សសុវណ្ណ** (Prawit wongsuwon) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ សហប្រធានគណៈកម្មាធិការព្រំដែនទូទៅថៃ ។

គោលបំណងនៃកិច្ចប្រជុំ នឹងផ្តោតយ៉ាងសំខាន់លើការពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាង កងទ័ពនៃប្រទេសទាំងពីរ **កម្ពុជា - ថៃ** ជាពិសេសក្នុងការរក្សា សន្តិភាព ស្ថេរភាព កិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរ និងដើម្បីទប់ស្កាត់រាល់អំពើអសកម្មមួយចំនួននៅតាមព្រំដែនរួមមាន: បញ្ហារត់ពន្ធគ្រឿងញៀន បញ្ហាប្រឆាំងអំពើភេរវកម្ម បញ្ហាបង្ក្រាបបទល្មើស ឧក្រិដ្ឋកម្មឆ្លងដែននានា ពិសេសការពង្រឹងសន្តិសុខតាមតំបន់ព្រំដែនដែលភាគីទាំងពីរនឹងពុះពារស្វែងរកដំណោះស្រាយ និងវិធានការទប់ស្កាត់ ដើម្បីរក្សា និងធានាអោយបាននូវស្ថេរភាព សន្តិសុខ និងការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី......... ខែ.............ឆ្នាំ២០១៧